# សន្ទរកថាស្វាគមន៍

## ទិវាអក្ខរកម្មអន្តរជាតិ ៨ កញ្ញាឆ្នាំ២០១៥

អ្នកស្រី **អាន ឡឺមៃត្រ** តំណាងអង្គការ យូណេស្កូប្រចាំនៅប្រទេសកម្ពុជា

**ខេត្តព្រៃវែង ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០១៥**

សូមគោរពឯកឧត្តម **បណ្ឌិត ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ឯកឧត្តម  លោកជំទាវ លោក/លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងប្រិយមិត្តទាំងអស់!

នាងខ្ញុំមានសេចក្តីសប្បាយរីករាយនិងមានកិត្តិយសចូលរួមក្នុងពិធីប្រារព្ធទិវាអក្ខរកម្មអន្តរជាតិនៅទីនេះជាមួយ ឯកឧត្តម លោកជំទាវ លោក/លោកស្រី ភ្ញៀវជាតិ អន្តរជាតិនិងប្រិយមិត្តទាំងអស់។ នាងខ្ញុំសូមថ្លែង អំណរគុណដល់ក្រសួងអប់រំ យុវជននិងកីឡាសម្រាប់ការប្រារព្ធទិវាដ៏មានសារៈសំខាន់នេះឡើង ព្រមទាំងសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតដល់ **ឯកឧត្តម** លោកជំទាវ លោក/លោកស្រីនិងប្រិយមិត្តទាំងអស់ជាពិសេសអ្នកដែលបានធ្វើដំណើរពីខេត្តនិងស្រុកឆ្ងាយៗមកចូលរួមក្នុងពិធីនេះ ។

**ឯកឧត្តម**  លោកជំទាវ លោក/លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងប្រិយមិត្តទាំងអស់ជាទីមេត្រី!

ឆ្នាំ២០១៥នេះគឺជាឆ្នាំដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជា ។ ដើម្បីឲ្យយុវជនកម្ពុជាក្លាយជាអក្ខរជនកាន់តែច្រើនឡើងនិងជាប្រជាពលរដ្ឋមានសិទ្ធអំណាច អង្គការយូណេស្កូមានសេចក្តីសប្បាយរីករាយធ្វើការជាដៃគូជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្នុងការអនុវត្តយុទ្ធនាការអក្ខរកម្មជាតិឆ្នាំនេះដើម្បីប្រមូលសិស្សអក្ខរកម្មជាជនពេញវ័យឲ្យបាន**៩២១២៥**នាក់នៅទូទាំងទាំងប្រទេស ។ រហូតមកដល់ពេលនេះ យើងមានសិស្សអក្ខរកម្មចំនួន**៧១៦១២**នាក់ហើយដែលបានចុះឈ្មោះនៅក្នុងថ្នាក់អក្ខរកម្មដែលក្នុងនោះមានប្រហែល៧០% ជាស្ត្រី ។ ដោយសារថ្នាក់អក្ខរកម្មទាំងនោះមាននៅទូទាំងប្រទេស យើងក៏ត្រូវការការជួយគាំទ្រនិងការលើកទឹកចិត្តពី **ឯកឧត្តម** លោកជំទាវ លោក/លោកស្រី និងអ្នកទាំងអស់គ្នានៅទីនេះដល់សិស្សអក្ខរកម្មឲ្យបន្តនៅរៀនសូត្ររហូតដល់ចប់ការសិក្សាផងដែរ ។ យើងក៏ត្រូវការការជួយគាំទ្រក្នុងការចុះតាមដាននិងជួយគាំទ្របច្ចេកទេសផ្សេ

ងៗទៀតៗដល់គ្រូអក្ខរកម្មទាំងអស់ដែលកំពុងបំពេញភារកិច្ចនិងការងារនៅតាមទីកន្លែងនិងភូមិនានាដែលមានការលំបាកនៅទូទាំងប្រទេស ។

ខ្ញុំចង់ចែករំលែកជាមួយ **ឯកឧត្តម** លោកជំទាវ លោក/លោកស្រីនូវពាក្យពេជន៍ខ្លះរបស់សិស្សអក្ខរកម្មដែលជាកម្មកររោងចក្រនៅក្នុងខេត្តកំពង់ឆ្នាំងពីបទពិសោធន៍នៃស្ថានភាពរស់នៅប្រចាំថ្ងៃជាអនក្ខរជន ។ នាងបានរៀបរាប់ប្រាប់ទាំងស្រក់ទឹកភ្នែកថា "*ដោយសារតែខ្ញុំមិនចេះអាននិងសរសេរ ដូចគេ ជាញឹកញាប់គេតែងតែហៅខ្ញុំថាជាមនុស្សល្ងង់ ដោយធ្វើការប្រៀបធៀបនាងខ្ញុំល្ងង់ដូចសត្វគោ ដូចជ្រូកឬសត្វឆ្មារ។ វាធ្វើឲ្យនាងខ្ញុំមានអារម្មណ៍អស់សង្ឃឹមនិងបាក់មុខមាត់ខ្លាំងណាស់*" ។

នាងបានប្តេជ្ញាចិត្តថានឹងខិតខំរៀនសូត្រឲ្យក្លាយទៅជាអ្នកចេះអក្សរដូចគេ ហើយក៏សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡាដែលបានផ្តល់ឱកាសដល់នាង ។ សិស្សអក្ខរកម្មដ៏ទៃទៀតក៏បានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនខិតខំរៀនឲ្យក្លាយទៅជាអ្នកចេះអក្សរនិងជួយអ្នកដ៏ទៃទៀតនៅក្នុងសហគមន៍របស់គេ ។

ទាំងអស់នេះគ្រាន់តែជាការដកស្រង់ខ្លះៗពីអារម្មណ៍ ពីទស្សនៈយោបល់ និងសារបានដែលយើងបានស្វែងយល់និងទទួលបានកន្លងមកតាមរយៈដំណើរទស្សនកិច្ចថ្នាក់អក្ខរកម្មនៅតាមសហគមន៍ ។ ប្រជាពលរដ្ឋដែលចង់ក្លាយជាអក្ខរជនគឺដើម្បីអាចឲ្យពួកគេធ្វើការសម្រេចចិត្តបានល្អពីជីវិតប្រចាំថ្ងៃរបស់ខ្លួននិងចូលរួមក្នុងការអភិវឌ្ឍសង្គម ។ អក្ខរកម្មមិនគ្រាន់តែជាការចេះអាន សរសេរ និងគិតលេខប៉ុណ្ណោះទេ ប៉ុន្តែះម្តាយដែលចេះអក្សរផ្តល់ចំណីអាហារទ្រទ្រង់រាងកាយដែលមានជីវជាតិ និងអនាម័យដល់កូនរបស់ពួកគេបានល្អប្រសើរ ឪពុកម្តាយដែលចេះអក្សរជួយកូនរបស់គេក្នុងការអាននិងសរសេរនៅផ្ទះ ឪពុកម្តាយដែលចេះអក្សរធ្វើឲ្យកុមារបោះបង់ការសិក្សាមានកម្រិតទាបនិងអត្រាបញ្ចប់ការសិក្សាមានកម្រិតខ្ពស់អ្នកដែលចេះអក្សរអាចទទួលបាននូវជំនាញបច្ចេកទេសនិងវិជ្ជាជីវៈលឿនជាងអ្នកមិនចេះអក្សរហើយជាលទ្ធផលគ្រួសារដែលចេះអក្សរនឹងមានប្រាក់ចំណូលខ្ពស់ជាងគ្រួសារដែលមិនចេះអក្សរ ។

**ឯកឧត្តម លោកជំទាវ លោក/លោកស្រី ភ្ញៀវជាតិ អន្តរជាតិ និងប្រិយមិត្តទាំងអស់ជាទីមេត្រី!**

នៅក្នុងអំលុងពេលដែលយើងទាំងអស់គ្នាទទួលស្គាល់ពីសារៈសំខាន់នៃអក្ខរកម្ម យើងក៏ទទួលស្គាល់ពីការលំបាកក្នុងការប្រមូលសិស្សអក្ខរកម្មដែលជាជនពេញវ័យឲ្យចូលរួមក្នុងថ្នាក់រៀនអក្ខរកម្មផងដែរ ។ មានបញ្ហាប្រឈមជាច្រើនដូចជាៈ បញ្ហាសេដ្ឋកិច្ច និងឱកាសការងារនៅតាមទីប្រជុំជនឬទីក្រុង និងការធ្វើចំនាកស្រុកជាដើម ។ នៅពេលដែលឱកាសការងារកាន់តែមានច្រើននៅតាមទីក្រុងកាលណា ប្រជាពលរដ្ឋនឹងធ្វើចំណាកស្រុកពីតំបន់របស់ខ្លួនពេលនោះដែរ នេះមានន័យ

ថានៅតាមតំបន់ជនបទនឹងមិនមានសិស្សឬពិបាកប្រមូលសិស្សអក្ខរកម្មជាជនពេញវ័យឲ្យចូលរៀនថ្នាក់អក្ខរកម្ម ។ ដូច្នេះជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដែលជាប្រធានបទនៃទិវាអក្ខរកម្មជាតិឆ្នាំនេះ យើងត្រូវការបង្កើតឱកាសនិងបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់សិស្សអក្ខរកម្មដែលបានធ្វើចំណាកស្រុកមកធ្វើការនៅតាមរោងចក្រនានានៅទីក្រុងភ្នំពេញ និងនៅតាមខេត្តផ្សេងៗទៀតដូចជាៈខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង និងស្វាយរៀងជាដើម ដូចដែលបានផ្តល់អនុសាសន៍ដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅក្នុងពិធីប្រកាសបើកយុទ្ធនាការអក្ខរកម្មជាតិជនពេញវ័យនៅថ្ងៃទី២ខែមីនាឆ្នាំ២០១៥កន្លងមកនេះ។ អង្គការយូណេស្កូសប្បាយរីករាយជួយគាំទ្រភាពជាអ្នកដឹកនាំរបស់ឯកឧត្តមលោកជំទាវក្នុងការលើកកម្ពស់ភាពជាដៃគូដើម្បីឈានទៅទទួលបានការប្រមូលសិស្សអក្ខរកម្មឲ្យកាន់តែច្រើនថែមទៀតនៅក្នុងឆ្នាំខាងមុខដើម្បីឲ្យប្រទេសកម្ពុជាបន្តរទទួលបាននូវការម្រេចគោលដៅអភិវឌ្ឍសហវត្សរបស់ខ្លួនក្នុងឆ្នាំ២០១៦-២០៣០ ដែលគោលដៅនោះផ្តោទៅលើបញ្ហាសំខាន់ៗដូចជាៈ បញ្ហាសមធម៌ គុណភាពអប់រំ និងទស្សនទាននៃការរៀនសូត្រពេញមួយជីវិត ។

ដូចដែលខ្ញុំបានលើកឡើងថា យើងត្រូវការការជួយគាំទ្រពីអ្នកទាំងអស់គ្នា ។ ឈរលើទស្សនៈទាននេះអង្គការយូណេស្កូសូមលើកទឹកចិត្តឲ្យមានការចូលរួមជាសកម្មពីសិស្សវិទ្យាល័យធ្វើជាអ្នកស្ម័គ្រជួយដល់ថ្នាក់អក្ខរកម្មតាមសហគមន៍ ។ នេះជាការផ្តល់តម្លៃនិងឱកាសដ៏វិសេសវិសាលដល់អ្នកស្ម័គ្រចិត្តវ័យក្មេងទាំងអស់នោះចូលរួមអភិវឌ្ឍសហគមន៍របស់ពួកគេ ។ សម្រាប់ការចូលរួមនិងការជួយរបស់យុវជនស្ម័គ្រចិត្តទាំងអស់នោះ ក្រសួងអប់រំយុវជននិងកីឡានិងអង្គការយូណេស្កូនឹងចេញជាលិខិតបញ្ជាក់ពីការចូលរួមរបស់ពួកគេ ហើយក្រុមហ៊ុនទូរស័ព្ទដៃស្មាតដែលជាដៃគូគាំទ្រយុទ្ធនាការជាតិអក្ខរកម្មនឹងផ្តល់ជាសេវាប្រើប្រាស់ប្រព័ន្ធហ្វេសប៊ុកដោយឥតបង់ប្រាក់រហូតដល់ខែធ្នូ ឆ្នាំ២០១៥ ។ អ្នកអាចមើលព័ត៌មានលំអិតនៅលើទំព័រហ្វេសប៊ុករបស់ក្រសួងអប់រំ យុវជននិងកីឡា របស់អង្គការយូណេស្កូ និងក្រុមហ៊ុនទូរស័ព្ទស្មាតបន្ថែមទៀត ។

**ឯកឧត្តម** លោកជំទាវ លោក/លោកស្រី ភ្ញៀវជាតិ អន្តរជាតិ!

អង្គការយូណេស្កូបានប្តេជ្ញាចិត្តជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ការរៀនសូត្រពេញមួយជីវិត ជាពិសេសតាមរយៈអក្ខរកម្មនិងការអភិវឌ្ឍជំនាញ សម្រាប់យុវជននិងជនពេញវ័យដើម្បីលើកកម្ពស់ធនធានធានមនុស្សនៅកម្ពុជា ។ ដូចដែលយើងបានសង្កេតឃើញក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកថាៈ មានសិស្សរបស់យើងជាច្រើនមិនបានបន្តការសិក្សារបស់ពួកគេនៅកម្រិតមធ្យមសិក្សាបឋមភូមិទេ អ្នកទាំងអស់នោះគឺជាធនធានមនុស្សដ៏មានសារៈសំខាន់មួយសម្រាប់ប្រទេសកម្ពុជា ។ មានឱកាសមួយសម្រាប់ជាជម្រើសដល់អ្នកទាំងអស់នោះឲ្យបានបញ្ចប់ការអប់រំ

កម្រិតមូលដ្ឋានបានគឺតាមរយៈកម្មវិធីសមមូលកម្រិតអប់រំមូលដ្ឋានផ្តោតលើគោលដៅយុវជនក្រៅសាលារៀន ។ អង្គការយូណេស្កូសប្បាយរីករាយធ្វើការជាមួយក្រសួង និងដៃគូពាក់ព័ន្ធដ៏ទៃទៀតគាំទ្រនូវគំនិតផ្តួចផ្តើមនេះ ។

ខ្ញុំសូមអរគុណដោយស្មោះអស់ពីដួងចិត្តចំពោះ**ឯកឧត្តម**រដ្ឋមន្ត្រី លោកជំទាវ និងថ្នាក់ដឹកនាំក្រសួងអប់រំ គ្រប់លំដាប់ថ្នាក់ដែលបានអញ្ជើញនាងខ្ញុំមកចូលរួមជាមួយនាថ្ងៃនេះ ។ នាងខ្ញុំក៏សូមអរគុណដល់ក្រុមហ៊ុនទូរស័ព្ទដៃស្មាតដែលបាននិងកំពុងជួយគាំទ្រក្នុងការលើកកម្ពស់យុទ្ធនាការអក្ខរកម្មជាតិជនពេញវ័យឆ្នាំ២០១៥ ។

ដូចដែលបានលើកឡើងដោយអគ្គនាយកអង្គការយូណេស្កូ អ្នកស្រី អ៊ីរីណា បូកូវា ថា៖ **អក្ខរកម្មត្រូវបានទទួលស្គាល់ថាគឺជាឈ្នាន់ពន្លឿនការអភិវឌ្ឍប្រកដោយនិរន្តភាពដ៏មានឥទ្ធិពលបំផុត ។ អនាគតចាប់ផ្តើមជាមួយអក្ខរក្រមនេះទៅ ។**

**សូមអរគុណ**!